**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :..២៦៧..វជអ.**

# បទបញ្ជាផ្ទៃក្នុង
# សម្រាប់គរុនិស្សិតសិក្សានៅ
# មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី

**យោង៖**-ប្រកាសលេខ: ១៩៦៦ អយក.ប្រក ចុះថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ នៅវិទ្យាស្ថានជាតិអប់រំ។

-លទ្ធផលជ្រើសរើសនិស្សិតចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ នៅវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩។

ដើម្បីឱ្យដំណើរការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ នៅវិទ្យាស្ថានជាតិអប់រំ មានភាពរលូន និងមានប្រសិទ្ធភាព សូមធ្វើការណែនាំដល់គរុនិស្សិត ដូចខាងក្រោម៖

**ប្រការ១:** **គោលបំណង**

បទបញ្ជាផ្ទៃក្នុងនេះ មានគោលបំណងរួមចំណែក ក្នុងការរៀបចំដំណើរការសិក្សា ដើម្បីឲ្យទទួលបានគុណភាព និងមានប្រសិទ្ធភាពខ្ពស់ ព្រមទាំងការអប់រំ គុណធម៌ និងសីលធម៌ ដែលជាកត្តាដ៏សំខាន់ក្នុងការលើកស្ទួយវិស័យអប់រំ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២:** **វិសាលភាព**

បទបញ្ជាផ្ទៃក្នុងនេះ សម្រាប់អនុវត្តចំពោះគរុនិស្សិត ដែលសិក្សានៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី នៃវិទ្យាស្ថានជាតិអប់រំតែប៉ុណ្ណោះ។

**ប្រការ៣:** **សំណុំលិខិតចុះឈ្មោះចូលរៀន**

ពាក្យសុំច្បាប់បន្តការសិក្សា សលាកបត្រឯកត្តជន កិច្ចសន្យា លិខិតធានា សេចក្តី ថ្លែងអំពីគោលបំណង ជីវប្រវត្តិរូបសង្ខេប និងរូបថត។ គ្រប់សំណុំលិខិតទាំងអស់ ត្រូវមានការបញ្ជាក់ ពីប្រធានអង្គភាព និងអាជ្ញាធរដែនដីដែលសាមីជនរស់នៅ។

**ប្រការ៤:** គរុនិស្សិតត្រូវមានសេចក្តីព្យាយាម អំណត់អត់ធ្មត់ ប្តូរផ្តាច់ និងមានទំនួលខុសត្រូវក្នុងការបំពេញនូវគ្រប់ភារកិច្ចរបស់ខ្លួន ដែលគ្រូឧទ្ទេសបានប្រគល់ជូន។

**ប្រការ៥:** គរុនិស្សិត ត្រូវតែបំពេញកិច្ចការគ្រប់ក្រេឌីត តាមការតម្រូវក្នុងកម្មវិធីសិក្សា។ ករណីដែលគរុនិស្សិត ខកខានមិនបានបំពេញ ឬធ្លាក់ក្រេឌីតណាមួយ ត្រូវធ្វើកិច្ចការនោះឡើងវិញ ។



អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៥ គេហទំព័រ៖ www.nie.edu.kh

**ប្រការ៦**: ក្នុងករណី ដែលមិនបានបំពេញគ្រប់លក្ខខណ្ឌតម្រូវរបស់កម្មវិធីសិក្សា គរុនិស្សិតត្រូវរៀនត្រួតថ្នាក់នៅឆ្នាំក្រោយ ដោយមិនមានការរក្សាទុក ប្រាក់ឧបត្ថម្ភឡើយ។ បើមិនព្រមបន្តការសិក្សាទេនោះ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីគរុនិស្សិត ហើយត្រូវសងប្រាក់អាហារូបករណ៍ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនរដ្ឋវិញ។

**ប្រការ៧**: គរុនិស្សិតត្រូវរៀបចំចរិយាសម្បត្តិឲ្យបានសមរម្យ ថ្លៃថ្នូរ សុភាពរាបសា មធ្យ័តជាគំរូល្អដល់សង្គម។ គរុនិស្សិតត្រូវពាក់បណ្ណសម្គាល់ខ្លួន នៅពេលចូលក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ។

**ប្រការ៨**: គរុនិស្សិតត្រូវមករៀនឱ្យបានទៀងទាត់ទាន់ពេលវេលា តាមពេលម៉ោងកំណត់ឲ្យបានម៉ត់ចត់ ចូលរៀនឲ្យបានគ្រប់ម៉ោង ដោយធានាឲ្យបានជាដាច់ខាត ចំពោះប្រសិទ្ធភាព និងគុណភាពនៃការសិក្សា។ការសុំច្បាប់ដោយមានធុរៈចាំបាច់ គរុ-និស្សិត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកគណៈគ្រប់គ្រងមជ្ឈមណ្ឌលឲ្យបាន មុនយ៉ាងតិច១ថ្ងៃ។

**ប្រការ៩**: **ម៉ោងពេលសិក្សារបស់គរុនិស្សិត**

- **ម៉ោងចូល-ចេញរបស់គរុនិស្សិត**
  - ✓ ពេលព្រឹកៈ ៧:០០ ដល់ម៉ោង១១:៣០។
  - ✓ ពេលរសៀលៈ ម៉ោង ១៣:៣0 ដល់ម៉ោង ១៧:00។
- **ការចាកចេញពីមជ្ឈមណ្ឌលមុនពេលកំណត់**
  - ✓ គរុនិស្សិត មិនត្រូវបានអនុញ្ញាតឲ្យចាកចេញពីមជ្ឈមណ្ឌលមុនម៉ោងកំណត់ដោយគ្មានការអនុញ្ញាត ពីគណៈគ្រប់គ្រងមជ្ឈមណ្ឌលឡើយ។

**ប្រការ១០**: **អវត្តមាន និងបទវិន័យ**

- គរុនិស្សិតអវត្តមានឥតច្បាប់ ៣ដងក្នុងមួយឆមាស ឬអវត្តមានទាំងមានច្បាប់ និងឥតច្បាប់ ៦ដង ក្នុងមួយឆមាស ត្រូវធ្វើគម្រោងសិក្សា ឬកិច្ចការស្រាវជ្រាវ បន្ថែមមួយទៀតដើម្បីបញ្ចប់តម្រូវការរបស់មុខវិជ្ជានីមួយៗដោយជោគជ័យ។
- ក្នុងករណី គរុនិស្សិតមិនបានបំពេញតាមលក្ខខណ្ឌខាងលើ គរុនិស្សិតនឹងត្រូវដាក់ពិន័យតាមលក្ខណ្ឌដែលមានចែងនៅក្នុងប្រការ៥ និងប្រការ ៦ *(សូមអានប្រការ៥ និងប្រការ៦ ឡើងវិញ)*។

**ប្រការ១១**: **សម្លៀកបំពាក់ និងការរៀបចំខ្លួន**

- គរុនិស្សិតទាំងអស់ត្រូវស្លៀកសម្លៀកបំពាក់តាមការកំណត់របស់វិទ្យាស្ថានជាតិអប់រំ *(អាវស ខោឬ សំពត់ពណ៌ខ្មៅ ឬខៀវ)*
- គរុនិស្សិតទាំងអស់ត្រូវតុបតែងខ្លួនឲ្យបានសមរម្យ *(ភាពឆើតឆាយ ខោឬសំពត់ខូប៊ូយ និងការលាបពណ៌សក់ ត្រូវបានហាមឃាត់ជាដាច់ខាត)*។

**ប្រការ១២**: គរុនិស្សិត ត្រូវចូលរួមចំណែកក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់មជ្ឈមណ្ឌល ដូចជាការប្រើប្រាស់សម្ភារបរិក្ខារសិក្សាផ្សេងៗរួមមានៈ តុ-កៅអី សម្ភារឧបទេស សម្ភារពិសោធ កុំព្យូទ័រ វិដេអូ សៀវភៅសិក្សា។ល។ និងរួមចំណែកសន្សំសំចៃការប្រើប្រាស់ ទឹក ភ្លើងអគ្គិសនី ជាដើម។

**ប្រការ១៣**: គរុនិស្សិត ត្រូវចូលរួមសកម្មភាពផ្សេងៗ តាមការតម្រូវរបស់មជ្ឈមណ្ឌល និង វិទ្យាស្ថានជាតិអប់រំ ដូចជា ចូលរួមសន្និសីទ សិក្ខាសាលា សកម្មភាពស្រាវជ្រាវ ការប្រជុំពាក់ព័ន្ធ ព្រមទាំងសកម្មភាព សង្គមមួយចំនួន តាមការចាំបាច់ជាក់ស្តែង។

**ប្រការ១៤**: គរុនិស្សិត ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន និងមានការទទួខុសត្រូវខ្ពស់ ក្នុងការសិក្សា ការពិភាក្សា កិច្ចការស្រាវជ្រាវ និងប្រធានបទ ឬកិច្ចការស្រាវជ្រាវ ដែល គ្រូឧទ្ទេសបានដាក់ឱ្យធ្វើ ឲ្យបានទាន់ពេលវេលាកំណត់ និងធានាបាននូវគុណ ភាព។

**ប្រការ១៥**: គរុនិស្សិតត្រូវបង្កើតទំនាក់ទំនងល្អ ជាមួយគណៈគ្រប់គ្រងគ្រប់ និង គ្រូឧទ្ទេស ដោយឈរលើស្មារតីសម្របសម្រួល និងអធ្យាស្រ័យគ្នាក្នុងការដោះស្រាយ រាល់បញ្ហា។

**ប្រការ១៦**: គរុនិស្សិត ទាំងអស់ ត្រូវមានវិន័យ និងប្រកាន់ខ្ជាប់ នូវក្រមសីលធម៌ និងត្រូវយកចិត្តទុកដាក់ចំពោះការសិក្សា ។

**ប្រការ១៧**: គរុនិស្សិតត្រូវមានការប្រុងប្រយ័ត្នក្នុងការនិយាយស្តី និងគិតដល់ពាក្យសម្តីរបស់ខ្លួន ចំពោះគរុនិស្សិតនិងសាធារណជន ក្នុងការផ្តល់ព័ត៌មានអំពីការអប់រំ ទាំងសាធារណៈ និងឯកជន។

**ប្រការ១៨**: គរុនិស្សិត មិនត្រូវធ្វើការរៃអង្គាសប្រាក់ ឬប្រមូលប្រាក់ក្រៅផ្លូវការ ឬធ្វើអាជីវកម្មនានាក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំឡើយ។

**ប្រការ១៩**: គរុនិស្សិត មិនត្រូវពាក់ព័ន្ធនឹងចលនា ឬនិន្នាការនយោបាយណាមួយ ឡើយ ហើយពិសេសមិនត្រូវនិយាយពាក្យសំដីណាដែលនាំឱ្យប៉ះពាល់ដល់ការ ដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាជាដាច់ខាត។

**ប្រការ២០**: ករណីគរុនិស្សិតរូបណាមិនបានប្រតិបត្តិតាមបទប្បញ្ញត្តិទាំងឡាយ ដូចបាន កំណត់ខាងលើ នោះត្រូវទទួលរងការដាក់ពិន័យពីមជ្ឈមណ្ឌលមានជាអាទិ៍: វិន័យរដ្ឋបាល ការស្តីបន្ទោសផ្ទាល់មាត់ ការស្តីបន្ទោសជាលាយលក្ខណ៍អក្សរ ការបញ្ឈប់ការសិក្សាដោយតម្រូវឱ្យសងប្រាក់អាហារូបករណ៍ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនរដ្ឋវិញ។ល។

**ប្រការ២១**: ករណីបំពានធ្ងន់ធ្ងរលើបទប្បញ្ញត្តិណាមួយនៃបទបញ្ជាផ្ទៃក្នុងនេះ ត្រូវធ្វើការវិនិច្ឆ័យសម្រេច ដោយក្រុមប្រឹក្សាវិន័យរបស់មជ្ឈមណ្ឌល ឬប្រគល់ជូនអាជ្ញាធរមានសមត្ថកិច្ចដោះស្រាយតាមផ្លូវច្បាប់។

**ប្រការ២២**: **ការផ្សព្វផ្សាយ**

បទបញ្ជាផ្ទៃក្នុងនេះ ត្រូវប្រជុំផ្សព្វផ្សាយដល់គ្រូឧទ្ទេស មន្ត្រី គរុនិស្សិត និងបិទផ្សាយជាសាធារណៈ។

**ប្រការ២៣**: **ការអនុវត្ត**

គរុនិស្សិត ដែលសិក្សានៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីទាំងអស់ ត្រូវគោរព និងអនុវត្តបទបញ្ជាផ្ទៃក្នុង នេះដោយមាន ការទទួលខុសត្រូវ និងឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

ចម្លងជូន៖

- ខុទ្ទកាល័យ ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី អយក.
- អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គណៈគ្រប់គ្រងមជ្ឈមណ្ឌល គ្រូឧទ្ទេស គរុនិស្សិត "ដើម្បីជ្រាប និងអនុវត្ត"
- កាលប្បវត្តិ- ឯកសារ វជអ